**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀងអំពីនិតិវិធីផ្អាកជាមួយកម្មករនិយោជិត

**យោង៖** - សេចក្តីណែនាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខ០៤៥/២០ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ ស្តីពីនិតិវិធីព្យួរកិច្ចសន្យាការងារតាមប្រព័ន្ធស្វ័យកម្ម

សេចក្តីដូចមានចែងក្នុងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោក/លោកស្រីប្រធានហជីព និងកម្មករនិយោជិតទាំងអស់**មេត្តាជ្រាបថាដោយសារតែមានការកាត់បន្ថយតម្រូវការសេវាកម្មផ្នែកសម្អាតពីព្រលានយន្តហោះអន្តរជាតិសៀមរាបយ៉ាងច្រើនសន្ធឹកសន្ធាប់ក្នុងកំឡុងពេលនៃការរីករាលដាលនៃកូវីដ១៩ នេះ ដូច្នេះក្រុមហ៊ុនអេច ស៊ី ស៊ី គ្រុប សាខាខេត្តសៀមរាបនឹងព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ១១៦នាក់ ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន១២៣នាក់ ដែលរយៈពេល០២ខែ ដោយគិតចាប់ពីថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០២០។

យើងខ្ញុំសូមជម្រាបជូនលោក/លោកស្រីប្រធានសហជីព និងកម្មករនិយោជិតទាំងអស់ មេត្តាជ្រាបថាការកាត់បន្ថយតម្រូវការសេវាកម្មសម្អាតនេះទៀតសោត ព្រលានយន្តហោះអន្តរជាតិសៀមរាប ក៏បានកាត់បន្ថយប្រាក់ចំណូលជាង ៩០%ផងដែរពីក្រុមហ៊ុនអេច ស៊ី ស៊ី គ្រុប ដូច្នេះក្រុមហ៊ុនពុំមានលទ្ធភាពបង់ប្រាក់ឈ្នួល និងអត្ថប្រយជន៍ផ្សេងៗ ជូនកម្មករនិយោជិតដែលព្យួរការងារបានទេ ។ ទោះជាយ៉ាងក៏ដោយក្រុមហ៊ុន(អេច ស៊ី ស៊ី) នៅតែរក្សាទំនាក់ទំនងល្អ ជាមួយកម្មករនិយោជិត និងទទួលពួកគាត់ឲ្យត្រលប់មកធ្វើការងារវិញ នៅពេលណាដែលស្ថានភាពល្អប្រសើរឡើងវិញ។

សៀមរាប ថ្ងៃទី....02.... ខែមិថុនា ឆ្នាំ២០២០

**តំណាងសហជីព**

សៀមរាប ថ្ងៃទី....02.... ខែមិថុនា ឆ្នាំ២០២០

**ភាគីខាងក្រុមហ៊ុន**

អេច ស៊ី ស៊ី គ្រុប
HCC Group Co., Ltd.